

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ការស្វែងយល់អំពី

# ល្ខោនខោល

ប្រភពឯកសារចម្បងដកស្រង់ចេញឯកសាររបស់

ឧកញ៉ាទេពពិទូ ក្រាសេម គន្ធបណ្ឌិត

Shared by page: Mr. That Chantha
https:///www.facebook.com/thatchantha

# អធិប្បាយរឿងល្ខោនខោល

## ១. ប្រវត្តិនៃល្ខោនខោលខ្មែរ

ល្ខោនខោល ឬ ល្ខោនពាក់របាំងមុខ គឺជាល្ខោនមួយ ដែលមានលក្ខណៈចំណាស់របស់កម្ពុជា មានដើមកំណើតនៃការសម្តែងមុនសម័យអង្គរ។ វាត្រូវបានគេជឿជាក់ថាបានចាប់ផ្តើមក្នុងអំឡុងប្រហែលសតវត្សទី៩ តាមរយៈចម្លាក់លឹប នៅតាមជញ្ជាំងអង្គរ។ ក្នុងសម័យអង្គរ ល្ខោនខោលត្រូវបានអភិវឌ្ឍដោយបុរសទាំងស្រុង ក្នុងការរាំប្រចាំ នៅព្រះរាជវាំងបុរាណខ្មែរ។ ហេតុផលដែលពិតប្រាកដនៅតែ មិនទាន់ដឹងច្បាស់ ប៉ុន្តែអ្នកស្រាវជ្រាវបានបង្ហាញថា ដោយសារការជុះដាលនៃសាសនាធ្វើឲ្យ សាសនាព្រាហ្មណ៍មានជម្លោះជាមួយសាសនាព្រះពុទ្ធ ក្នុងរាជកាលព្រះបាទជ័យវរ្ម័នទី៧(១២៤៣- ១២៩៥)។ ក្នុងនោះមាននារីរបាំជាច្រើនត្រូវបានសម្លាប់ និងធ្វើជាស្រីកំណាន់ ដូច្នេះទើបមាន ការហ្វឹកហាត់អ្នករបាំបុរស ដើម្បីបង្កើតរបាំនេះផ្អែកទៅលើលិទ្ធអ្នកកាន់សាសនាព្រះពុទ្ធ។

រឿងមួយទៀត ដែលជាក់លាក់អំពីការសម្តែងដោយល្ខោនខោលគឺ រឿងរាមកេរ្តិ៍ ដែលជារឿងព្រេងរបស់ខ្មែរ សម័យរាមាយណៈ។ ការសម្តែង រួមបញ្ចូលនូវការប្រាប់អំពីអ្នកនិទានរឿង ដែលដើរតួ សំខាន់ក្នុងការសម្តែង និងវង់ភ្លេងបុរាណគឺ វង់ភ្លេងពិណពាទ្យ។ ល្ខោនគឺមានប្រជាប្រិយភាព ក្នុងសម័យលន់នល់ និងពេលបន្ទាប់មកក៏ក្លាយជាមហេសីសំណព្វរបស់ស្តេច សីហនុ។ ពេលនោះមាន៨ក្រុមល្ខោនដែលមានជំនាញ ហើយបន្ទាប់មកត្រូវបែកខ្ញែកដោយសារសង្គ្រាម តែនៅពេលបច្ចុប្បន្ននេះនៅសល់តែមួយក្រុមគឺនៅ វត្តស្វាយដង្គុំ ចំងាយ ១៥គីឡូម៉ែត ពីទីក្រុងភ្នំពេញ។ ក្រុមថ្មីពីរ ទៀតបានចាប់ផ្តើមក្នុងសង្គ្រាមរួមមានក្រុមកំពង់ធំ និងក្រុមល្ខោនជាតិ ដែលមកពីមន្ទីរវិចិត្រសិល្បៈ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ល្ខោនខោលនេះ ក៏រាប់រួមនៅក្នុងល្ខោនដរ តែមានបំណងដោយឡែកផ្សេងអំពីល្ខោន គឺល្ខោននោះគេលេងរឿងផ្សេងៗមិនមានកំណត់ ចំណែកឯល្ខោនខោលនោះគេកំណត់លេងចំពោះតែរឿងដែលទាក់ទាមដោយរឿងព្រះជាម្ចាស់ គឺព្រះឥសូរ ព្រះនារាយណ៍ ដែលជាព្រះក្នុងសេយ្យសាស្ត្រ គឺលេងរឿងអវតា (បែងភាគ) សឹងជាប្រវត្តិរបស់ព្រះជាម្ចាស់នោះ ដើម្បីប្រកាសកិត្តិគុណសេចក្តីខ្លាំងពូកែនឹងក្លាហានរបស់ព្រះជាម្ចាស់ នឹងអ្នកដែលព្រះជាម្ចាស់បានបែងភាគឲ្យមកកើត ដូចយ៉ាងព្រះរាម, តាមក្នុងក្បួនថា លេងរឿងដូច្នេះជាហេតុឲ្យកើតមង្គលសួស្តីដល់អ្នកលេង នឹងជាទីប្រោសប្រាណរបស់ព្រះជាម្ចាស់ ទើបគេ

និយមលេងមកដល់ឥឡូវនេះ តែមនុស្សក្នុងសម័យនេះមិនសូវមានអ្នកយល់ដូចពោលមកខាងលើនេះទេ គេយល់ត្រឹមតែថាជា មហោស្រព ១ យ៉ាងសម្រាប់លេងជាគ្រឿងសប្បាយរីករាយ ហើយក៏លេងតាមកាល តាមសម័យដែលគួរលេង តាមប្រក្រតីមានលេងតែក្នុងព្រះរាជពិធីធំ ៗ របស់ស្ដេចផែនដី អ្នកក្រៅមិនដែលឃើញមានលេងទេ ។

រឿងអវតារនោះ មានដល់ទៅ ១០ រឿង, ៩ រឿងខាងដើមជារឿងដែលមានរួចមកហើយ នៅ ១ រឿងខាងចុងបំផុតថា នឹងមានមកក្នុងអតីតកាល ក្នុង ១០ រឿងនោះរាប់រឿងរាមកេរ្តិចូលមួយថាជារឿងព្រះអវតាររឿងនេះក្នុងប្រទេសកម្ពុជាមានគេចេះដឹងដោយច្រើន រឿងឯទៀតជារបស់កំបិទកំបាំង មិនសូវមានអ្នកណាចពដឹង ហេតុនោះ តែកាលណាត្រូវលេងល្ខោនខោល គេក៏លេងតែរឿងរាមកេរ្តិនោះឯង ក្នុងរឿងនោះមានទាំងមនុស្ស ទាំងយក្ខ ទាំងស្វា ៣ សាសន៍ផងគ្នា, ពួកអ្នកលេងអំបាលនោះក៏តោងហាត់ក្បាច់លេងផ្សេងគ្នា តាមភាពរបស់អ្នកទាំង ៣ សាសន៍នោះ គឺអ្នកដែលត្រូវធ្វើជាមនុស្ស (រួមទាំងទេវតាផង) ក៏ហាត់រាំតាមលំនាំក្បាច់រាំក្នុងបរិច្ឆេទទី ២ ដែលពោលមកហើយ អ្នដែលត្រូវធ្វើជាយក្ខនឹងស្វាផ្សេងទៅទៀតក្បាច់រាំបែបនេះ មិនដែលប្រទះឃើញក្បួនខ្នាតដើមដែលជាឫសគល់នោះទេ ជាមានដូម្តេចខ្លះ ប៉ុន្មានបែបប៉ុន្មានយ៉ាង មិនប្រាកដ អ្នកហាត់រាំតោងអាស្រ័យសិក្សាត ៗ មកដរាបដល់សព្វថ្ងៃនេះ តែតាមដែលរួបរួមក្នុងវេលានេះ ឃើញក្បាច់យក្ខមាន ... យ៉ាង ក្បាច់ស្វាមាន ... ដូចមានតទៅនេះ ។

## ២. ក្បាច់ល្ខោនខោល ក្បាច់យក្ខ

### ក្បាច់ទសកណ្ឋចេញស្ដីរាជការទី ១

របៀបបង្គុយ – ទសកណ្ឋទ្រង់គ្រឿងរាជ្យពេញយស អង្គុយលុតជង្គង់លើព្រះទែន ដៃទាំងពីរកាន់អាវុធរូបនាគចុងដើម មុខទ្រង់ងើយស្ងើនឡើងបន្តិច ជាកិរិយាសំដែងអានុភាពដ៏ឃោរឃៅ ។

### ក្បាច់ទសកណ្ឋចេញស្ដីរាជការទី ២

របៀបអង្គុយ – ទសកណ្ឋទ្រង់គ្រឿងដូចមុន អង្គុយបញ្ឈរជង្គង់ខាងស្ដាំ ទម្រេតខ្លួនទៅខាងឆ្វេងបន្តិច ដៃស្ដាំកាន់អាវុធរូបនាគ ដាក់ដៃគងលើជង្គង់ស្ដាំ ឲ្យចុងដៃនឹងជង្គង់ស្មើគ្នា, ជាកិរិយាសំបើម ។

## ក្បាច់ទសកំណ្ឋចេញស្តីរាជការទី ៣

របៀបអង្គុយ – អង្គុយតាមឥរិយាបថដូចទី ២ ប្លែកតែផ្ងៀងក្បាលទៅខាងស្តាំបន្តិច ដៃកាន់អាវុធដាក់លើជង្គង់ស្តាំ ត្រង់ពាក់កណ្តាលកំភួនដៃ ។

## ក្បាច់យក្ខទី ១

របៀបរាំ – ឈរបោះជើងឆ្វេងទៅមុខយ៉ាងពេញជំហាន បង្អើចមេជើងឲ្យតាំងឡើងលើ ដៃឆ្វេងលើករាចេញទៅមុខ មេដៃបំបត់មករកបាតដៃ, ដៃស្តាំដាក់ទៅស្តាំ កាន់អាវុធបញ្ឈរគល់ឡើងលើ ។

## ក្បាច់យក្ខទី ២

របៀបរាំ – ឈរបង់ជំទែងញែកជង្គង់ចេញទាំងសងខាង ចំអើតខ្លួនចេញទៅស្តាំខ្លះ ទៅឆ្វេងខ្លះ ដៃស្តាំកាន់អាវុធពាក់កណ្តាលលើកងាឡើង, ដៃឆ្វេងដាក់ចុះក្រោមបំពត់ខ្នងដៃចូលក្នុង ម្រាមចង្អុលដៃចង្អុលចាំមកភ្លៅឆ្វេងរបស់ខ្លួន ។

## ក្បាច់យក្ខទី ៣

របៀបរាំ – ដូចគ្នានឹងបែបទី ២ ប្លែកតែដៃឆ្វេងផ្ងារបាតដៃចេញ ឲ្យម្រាមដៃចុះក្រោម ។

## ក្បាច់យក្ខទី ៤

របៀបរាំ – ឈរបង់ជំទែងពេញទី ជង្គង់ទាំងពីរវ៉ាតចេញទៅខាងទាំងសងខាង, ដងខ្លួនតាំងត្រង់, ដៃឆ្វេងលើកខ្ពស់ហុចទៅឆ្វេង ផ្ងារបាតដៃ ឲ្យម្រាមដៃទាំង ៤ សំយុងចុះក្រោម មេដៃបំពត់ទទឹងបាតដៃ, ដៃឆ្វេងកាន់អាវុធត្រង់ពាក់កណ្ដាលយកមកផ្ទប់នៅពោះ ។

## ក្បាច់យក្ខទី ៥

របៀបរាំ – ឈរបង់ជំទែងពេញទី ជង្គង់ទាំងពីរវ៉ាតចេញទៅឆ្វេងទៅស្តាំ ដងខ្លួនទម្រេតមកខាងស្តាំបន្តិច មុខមើលផៀងទៅឆ្វេង, ដៃឆ្វេងលើកខ្ពស់ ហុចទៅឆ្វេង ដូចក្បាច់ទី ៤, ដៃស្តាំគាន់អាវុធត្រង់ពាក់កណ្តាល ឲ្យខាងគល់ឡើងលើ ហើយលោតត្រង់ចេញទៅស្តាំ ។

## ក្បាច់យក្ខទី ៦

របៀបរាំ – ឈរបង់ជំទែងដូចក្បាច់ទី ៥ តែបញ្ចប់ជង្គង់ឆ្វេងឲ្យញោចទៅខាងឆ្វេងបន្តិច, ដៃឆ្វេងលើករាទៅឆ្វេង តែឲ្យម្រាមទ្រេតមកក្រោយ, ដៃស្តាំកាន់អាវុធត្រង់ពាក់កណ្តាល ឲ្យគល់ចុះក្រោម លើកយារទៅស្តាំ ។ មុខងើយបែបក្រឡេកមើលឆ្ងាយ ។

## ៣. ឧសភណ្ឌចូលឧទ្យាន

របៀបតែងខ្លួន – តែងពេញយសដូចមុន តែគ្មានកាន់អាវុធ ទៅជាកាន់ផ្លិតក្រដាសជំនួស នឹងប្រដាប់ដោយផ្កាក្រងនៅដៃស្តាំ ត្រចៀកស្តាំបង់ក្រមាសំយោកជាយទាំងពីរទៅក្រោយ សំដែងកិរិយាសប្បាយរីករាយ ។

## ឧសភណ្ឌរាំ
## ក្បាច់ដដាយទី ១

របៀបរាំ – តែងខ្លួនដូចកាលចូលឧទ្យាន តែគ្មានកាន់ផ្លិត, ដំបូងចេញមក ដៃទាំងពីរផ្ទឹមចង្កេះ ។

## ឧសភណ្ឌរាំ
## ក្បាច់ដដាយទី ២

របៀបរាំ – ឈរជាជំហរយក្ខ គឺឈរបង់ជំទែង តែបន្ទោរជង្គង់នឹងខ្លួនទៅឆ្វេងបន្តិច ដៃឆ្វេងជីបម្រាមពីរដាក់ប្រទល់គ្នានឹងដៃស្តាំ ពីខាងមុខដៃស្តាំនោះគៀនផ្លិតផង ។

## ឧសភណ្ឌរាំ
## ក្បាច់ដដាយទី ៣

របៀបរាំ – ឈរដោយជើងស្តាំ ជើងឆ្វេងលើកខ្ពស់, ដៃទាំងពីរលើកហុចត្រង់ទៅមុខ នឹងជីបម្រាមពីរទាំងសងខាង តែដៃស្តាំនោះគៀនផ្លិតផង ។

## ទសកណ្ឋរាំ

## ក្បាច់ជជាយទី ៤

របៀបរាំ – ឈរដោយជើងស្តាំ បន្ទន់ជង្គង់ទៅមុខបន្តិច, ជើងឆ្វេងលើកខ្ពស់ សំយុងចុងជើងចុះក្រោម ដៃឆ្វេងត្រង់ចេញទៅឆ្វេង ជីបម្រាមពីរឡើងលើ ម្រាមឯទៀតលាក្រញាងចេញ, ដៃស្តាំបោះទៅក្រោយ ឲ្យចុងដៃសណ្តូកចុះទាបបន្តិច ជីបម្រាមពីរ នឹងត្បៀតផ្តិតផង ។

## ទសកណ្ឋរាំ

## ក្បាច់ជជាយទី ៥

របៀបរាំ – ឈរឈានជើងឆ្វេងទៅមុខ, ដងខ្លួនបន្ទោរទៅមុខផៀងឆ្វេងបន្តិច ដៃឆ្វេងធ្វើក្រងុងចេញទៅមុខ ដៃស្តាំបោះទៅក្រោយ ត្បៀតផ្តិតបញ្ឈរឡើង ទាំងរំសាយផ្តិតឲ្យលាចេញផង ។[1]

## ក្បាច់ភ្លេងរួស

របៀបរាំ – ឈរបន្ទន់ជង្គង់ចេញទៅខាង ចុងជើងទាំងពីរក៏បំបែរចេញទៅខាង ៗ ដៃទាំងពីរលើកជ្រែងចេញទៅ ហើយបំពត់ចុងដៃមករកខ្លួន, មុខទ្រង់ងើយបន្តិច ក្នុងខណៈនេះ ទន្រ្តំជើងទាំងពីរផង ។ (វេលានោះភ្លេងនឹងប្រែបទលេងឲ្យរួស) ។

## ទសកណ្ឋសោក

របៀបឥរោយាបថ – អង្គុយបត់ជង្គង់ឆ្វេងដាក់រាប បញ្ឈរជង្គង់ស្តាំ ដៃស្តាំដាក់គងលើជង្គង់ស្តាំ ហើយចាប់កាន់ដៃឆ្វេង បន្ទន់ក្បាលទៅខាងស្តាំធ្វើល្មៀក សំដែងកិរិយាទុក្ខសោក ។ អាវុធដាក់ខាងខ្លួន ។

មេក្បាច់ធំ របស់ក្បាច់យក្ខមានតែប៉ុណ្ណេះ វេលារាំតោងរាំទៅជាលំនាំផ្សេង ៗ ដើម្បីភ្ជាប់តពីក្បាច់ ទៅក្បាច់ ត្រង់កន្លែងខ្លះក៏យកក្បាច់រាំរបស់មនុស្សនោះទៅរាំផង ត្រង់កន្លែងដែលសំខាន់ ៗ ទើបបញ្ចេញក្បាច់យក្ខពេញទី ។

[1] ផ្តិតដែលកាន់នៅដៃ មិនជាសំខាន់ប៉ុន្មាន ទោះបីមានកាន់ក៏បាន មិនមានក៏បាន ខសំខាន់នៅត្រង់ក្បាច់រាំ ។

## ៤. អធិប្បាយក្បាច់ស្វា

អ្នកដែលត្រូវធ្វើជាស្វា គេតែងខ្លួនទំនងជាស្វានឹងពាក់មុខរូបស្វា ជាស្វាសឬស្វាខ្មៅ តោងស្លៀកពាក់ពណ៌តាមនោះ បើជាស្ដេចស្វាតោងមានពាក់សង្វាផង ។

### ក្បាច់ស្វាទី ១

របៀបរាំ – ឈរបង់ចំទែងពេញទី បន្ទន់ជង្គង់ឲ្យញោចទៅខាងមុខបន្តិច ខ្លួនចំអើតចេញទៅមុខឆៀងស្តាំ ដៃស្តាំកាន់អាវុធខ្លី គឺជាត្រីសូល ឬដំបងខ្លី ឲ្យចុងចុះក្រោម ។

### ក្បាច់ស្វាទី ២

របៀបរាំ – របៀបជំហរដូចទី ប្លែកតីដៃឆ្វេងលើកលាតចេញទៅមុខ ហើយបំបត់កដៃចូលមកនឹងជីបម្រាមពីរ ដៃស្តាំកាន់អាវុធដាក់ពីមុខត្រង់វាងពោះ បំបត់កដៃចុះក្រោម ឲ្យចុងអាវុធឡើងលើ តែឲ្យនៅពីក្រៅដៃ ។

### ក្បាច់ស្វាទី ៣

របៀបរាំ – កិរិយាជំហរដូចមុន ប្លែកតែដៃឆ្វេងច្រត់ចុះត្រង់វាងពាក់កណ្ដាលផ្លូវ ដៃស្តាំកាន់អាវុធលើកងាឡើង ឲ្យចុងអាវុធចុះស្របតាមដៃ ។

### ក្បាច់ស្វាទី ៤

របៀបរាំ – កិរិយាជមហរដូចមុន ប្លែកតែដៃឆ្វេងដាក់ផ្ងារចេញទៅមុខ តែឲ្យដៃទាបចុះ ដៃស្តាំលើកងាឡើង ឲ្យចុងអាវុធឡើងលើ ។

### ក្បាច់ស្វាទី ៥

របៀបរាំ – កិរិយាជំហរដូចមុន ប្លែកតែដៃឆ្វេងលើកខ្ពស់ចេញទៅមុខ ម្រាមដៃធ្វើបែបជាមាត់ស្វាហា ។

### ក្បាច់ស្វាទី ៦

របៀបរាំ – កិរិយាជំហរនឹងលើកដៃដូចមុន ប្លែកតែកដៃឆ្វេងបត់ចូលហើយជីបម្រាមពីរ ។

## ក្បាច់ដើត

របៀបរាំ – ក្បាច់នេះដូចគ្នានឹងក្បាច់ទី ៥ ប្លែកតែក្បាច់នេះដៃឆ្វេងដាក់ត្រង់ស្មើចេញទៅមុខ ។

## ក្បាច់មើលចំហៀង

របៀបរាំ – ឈរញែកជើងចេញ បញ្ចាក់ជង្គង់ចេញទៅឆ្វេងទៅស្តាំ ខ្លួនអើត មើលទៅចំហៀងខាងឆ្វេង, ដៃឆ្វេងធ្វើដូចក្បាច់ទី ៥, ដៃស្តាំកាន់អាវុធដាក់ពីមុខភ្លៅ ឲ្យចុងចេញទៅក្រៅ ។

## ក្បាច់ស្វាលង់ទ្រនេស

របៀបរាំ – ដើរបន្ទន់ជង្គង់ ដៃឆ្វេងដាក់លើជង្គង់ឆ្វេង ដៃស្តាំយូរឡើង ខ្លួនផ្អៀង បត់កញ្ចៀក ជាកិរិយាអស់កម្លាំងល្ហិតល្ហៃ ។

## ក្បាច់គគ្រាម

របៀបរាំ – ជើងឆ្វេងបោះទៅមុខ បញ្ឈរជង្គង់ឡើង ជើងស្តាំសណ្តូកត្រង់ទៅក្រោយ ដៃទាំងពីរដាក់ត្រៀបលើជង្គង់ឆ្វេង ខ្លួនអើតទៅលើជង្គង់ឆ្វេងនោះ ។

## ក្បាច់ឆក់

របៀបរាំ – អង្គុយចំគោត ដៃឆ្វេងយូរដាក់ពីមុខ ដៃស្តាំលូកទៅខាងស្តាំខ្លួន, មូលខ្លួនងាកមើលទៅឆ្វេងផៀងខាងក្រោយ ។

## ក្បាច់លប

របៀបរាំ – ជើងឆ្វេងបោះទៅមុខ បញ្ឈរជង្គង់ជើងសណ្តូកទៅក្រោយ បែរមុខផៀងទៅឆ្វេង ដៃទាំងពីរយូរដាក់ពីមុខ ជាអាការស្វាតែងធ្លាប់ធ្វើដូច្នោះ ។

### ៥. ឯកសារយោង

ប្រភពឯកសារដែលរៀបរៀងដោយ ឧកញ៉ាទេពពិទូ ក្រសេម គន្ថបណ្ឌិត

https://km.wikipedia.org/wiki/ល្ខោនខោល